**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៦.០៨៩/០៨ គ.ជ.ប.អគ្គ.ពស**

ភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៨

# សន្លឹកឆ្នោតលម្អៀង និងសន្លឹកឆ្នោតបម្រុង

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) កំពុងផលិតសន្លឹកឆ្នោតចំនួន ១០.៤៥៤.៤០០សន្លឹក សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ឆ្នាំ២០០៨ នេះ ។ សន្លឹកឆ្នោតត្រូវបានបោះពុម្ពជា២៤ប្រភេទផ្សេងគ្នាទៅតាមមណ្ឌលបោះឆ្នោតនីមួយៗ ។ សន្លឹកឆ្នោតនៃមណ្ឌលបោះឆ្នោតណាប្រើបានតែនៅមណ្ឌលបោះឆ្នោតនោះប៉ុណ្ណោះ ។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា សន្លឹកឆ្នោតដែលត្រូវផលិតមានចំនួន ១០.៤៥៤.៤០០ សន្លឹក ស្មើនឹង ២០៩.០៨៨ក្បាល(១ក្បាលស្មើនឹង៥០សន្លឹក) កំពុងផលិត ដោយរោងពុម្ពមួយរបស់ក្រុមហ៊ុន លី វ៉ាន់ហុង ដែលមានទីតាំងស្ថិតនៅផ្ទះលេខ៩ ផ្លូវ៣៤៥ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ឯកឧត្តមបានបញ្ជាក់ថា ចំនួនសន្លឹកឆ្នោតដែលត្រូវបោះពុម្ព គឺផ្អែកតាមចំនួនអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០០៧ ដែលមានចំនួន ៨.១២៥.៥២៩នាក់ បូកនឹងសន្លឹកឆ្នោតបម្រុង ។

ក្នុងមួយការិយាល័យបោះឆ្នោតមានសន្លឹកឆ្នោតលម្អៀងពី ០ ទៅ ៤៩សន្លឹក ។ ចំពោះករណីសន្លឹកឆ្នោតលម្អៀង ឯកឧត្តម ទេព នីថា បានលើកឧទាហរណ៍ថា បើការិយាល័យបោះឆ្នោតមួយមានអ្នកបោះឆ្នោតចំនួន ៣០០នាក់ នោះសន្លឹកឆ្នោតដែល គ.ជ.ប បញ្ជូនទៅឱ្យការិយាល័យបោះឆ្នោតមានចំនួន ៣០០សន្លឹក ស្មើនឹង ៦ក្បាល (១ក្បាល មានចំនួន៥០សន្លឹក) ហើយត្រូវឱ្យសន្លឹកឆ្នោតបម្រុងចំនួន ៥០សន្លឹក ទៅការិយាល័យបោះឆ្នោតនោះថែមទៀត ។ ករណីនេះកម្រិតលម្អៀងនៃសន្លឹកឆ្នោតគឺ ០ សន្លឹក ។ ប៉ុន្តែបើការិយាល័យបោះឆ្នោតមួយមានចំនួនអ្នកបោះឆ្នោត ៣០១នាក់ នោះសន្លឹកឆ្នោតដែល គ.ជ.ប បញ្ជូនទៅឱ្យការិយាល័យបោះឆ្នោតមានចំនួន ៣៥០សន្លឹក ស្មើនឹង ៧ក្បាល ។ ដូច្នេះកម្រិត លម្អៀងនៃសន្លឹកឆ្នោតគឺមានចំនួន ៤៩ សន្លឹក ហើយការិយាល័យបោះឆ្នោតនោះក៏ត្រូវទទួលសន្លឹកឆ្នោតបម្រុងចំនួន ៥០សន្លឹកដែរ ។

ក្រៅពីសន្លឹកឆ្នោតបម្រុងនៅការិយាល័យបោះឆ្នោត គ.ជ.ប ផ្តល់សន្លឹកឆ្នោតបម្រុងឱ្យរក្សាទុកនៅ គឃ/កប ចំនួន ៧៥០ សន្លឹក ក្នុង ១ ឃុំ សង្កាត់ ហើយចំនួនសន្លឹកឆ្នោតបម្រុងនេះមានតិច ឬច្រើននៅក្នុងខេត្ត ក្រុង វាអាស្រ័យទៅនឹងចំនួនឃុំ សង្កាត់ នៃខេត្ត ក្រុងនីមួយៗ ។ សន្លឹកឆ្នោតបម្រុងដែលទុកនៅ គឃ/កប នេះគឺត្រៀមប្រើប្រាស់សម្រាប់ក្នុងករណីប្រធានស័ក្តិ ។ ការិយាល័យបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ឆ្នាំ២០០៨នេះ មានចំនួន ១៥.២៥៥ការិយាល័យ ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងទូរស័ព្ទលេខ: ០២៣ ២១៤ ៣៧៤ / ០១២ ៨៥៥ ០១៨ E-mail: necinfo@forum.org.kh, Web-site: www.necelect.org.kh